អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងស្តាប់**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

បំណិនចលកធំ (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំតូចនិងសាច់ដុំធំ)។

**ភាសាខ្មែរ**

ស្តាប់ (ស្តាប់គេនិយាយនិងមានសមត្ថភាពស្តាប់ដោយធ្វើតាមការណែនាំដោយងាយៗ)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។
បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(ភាសាខ្មែរ)** ប្រាប់បានពីសម្ថភាពតាមដំណាក់កាលដោយអនុវត្តតាមការណែនាំប្រាប់ពីសូរសម្លេងនិងឈ្មោះនានាក្នុងបរិស្ថាន។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ អ្វីដែលអាចចងភ្នែកបាន បិទបាំងភ្នែកបាន។

**ការរៀបចំ** ៖ ឱ្យក្មេងឈរជារង្វង់ មានក្មេងម្នាក់អង្គុយកៅអី មានកំណាព្យ។

**សេដក្តីណែនាំ៖**

1. និយាយ៖ ថ្ងៃនេះអ្នកគ្រូនឹងលេង**ល្បែងស្តាប់** ជាមួយកូនៗទាំងអស់គ្នា។
2. ប៉ុន្តែកូនៗត្រូវឈរជារង្វង់។
3. បន្ទាប់មកដាក់កៅអីមួយនៅចំកណ្តាលរង់។
4. បង្រៀនក្មេងឱ្យនិយាយតាមនូវកំណាព្យ ៤ឃ្លាខាងក្រោមគឺ៖

   ខ្ញុំរីករាយ ខ្ញុំក្រៀមក្រំ
   ខ្ញុំខឹង ខ្ញុំត្រេកអរ
   ខ្ញុំសើច ឬ ខ្ញុំយំ
   ប៉ុន្តែ ខ្ញុំជានរណា?
5. ជ្រើសរើសក្មេងណាម្នាក់ឱ្យអង្គុយលើកៅអីចំកណ្តាល។
6. ត្រូវមានក្រមាបិទភ្នែក តែប្រសិនបើគ្មានក្រមាទេនោះ អាចប្រើដៃបាំងភ្នែកក៏បានដែរ។

7. បន្ទាប់មកឱ្យក្មេងៗទាំងអស់និយាយកំណាព្យ៤ឃ្លានោះបណ្ដើរនឹងដើរជារង្វង់បណ្ដើរ។
8. នៅពេលដែលក្មេងៗនិយាយកំណាព្យនោះចប់ហើយ ក្មេងក៏ត្រូវតែឈប់នៅមួយកន្លែងដែរ។
9. បន្ទាប់មកគ្រូឱ្យកុមារណាម្នាក់ដែលនិយាយឃ្លាប្រយោគនោះ ហើយឈរនៅទីណាវិញក៏បាននៃរង្វង់ដែលពួកគេកំពុងឈរនោះ
10. កុមារអាចឈរនៅកន្លែងដែលនិយាយប្រយោគក៏បាន ឬអាចផ្លាស់ប្ដូរកន្លែងក៏បាន ទៅតាមការរៀបចំរបស់អ្នកផងដែរ។
11. បន្ទាប់មកក្មេងដែលអង្គុយលើកៅអីកណ្ដាលរង់ត្រូវទាយថា តើនោះជានរណា? ឈ្មោះអ្វី? ។
12. ប្រសិនបើក្មេងនោះទាយត្រូវ នោះម្នាក់នោះត្រូវមកអង្គុយលើកៅអីកណ្ដាលរង់វិញម្ដង។
13. បន្ទាប់មកក្មេងៗទាំងអស់ចាប់ផ្ដើមដើរជារង្វង់ និងសូត្រកំណាព្យឬប្រយោគនោះបន្តទៀត។
14. ធ្វើបែបនេះរហូតដល់ក្មេងៗអាចបានលេងគ្រប់ៗគ្នាជាការស្រេច។